ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា
ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

# សេចក្តីជូនដំណឹង

គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា នាថ្ងៃចន្ទ ៦កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ នេះ នាវេលាម៉ោង ១១:៣០នាទីព្រឹក នៅទីស្តីការក្រសួងការងារថៃ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការបានដឹកនាំប្រតិភូកម្ពុជាទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសថៃ ដើម្បីជួបសំដែងការគួរសម និងពិភាក្សាការងារផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាជាមួយឯកឧត្តមឧត្តមសេនីយ៍ Po. Gen. ADUL SANGSINGKEO រដ្ឋមន្ត្រីក្រសួងការងារថៃ។ កិច្ចពិភាក្សានេះបានប្រព្រឹត្តទៅក្រោមបរិយាកាសយោគយល់ ស្និទ្ធស្នាល និងទទួលបានលទ្ធផលជាវិជ្ជមាន ដូចខាងក្រោម៖

១. សម្តែងនូវការអបអរសាទរចំពោះកិច្ចសហប្រតិបត្តិការ ក្នុងយុទ្ធនាការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលគិតត្រឹមថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨ នេះ ប្រទេសទាំងពីរបានរួមគ្នាផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ចំនួន ១លាន ៧ម៉ឺននាក់ក្នុងនោះ៖

- បានសហការគ្នាបញ្ជាក់អត្តសញ្ញាណថ្មីជូនពលករកម្ពុជាដែលមានប័ណ្ណស៊ីជម្ពូ (ប័ណ្ណមិនមែនសញ្ជាតិថៃ) ដែលចេញដោយភាគីថៃ ដើម្បីយកទៅសុំភាពស្របច្បាប់ពីភាគីថៃ បានចំនួនប្រមាណ ៤២ម៉ឺននាក់។
- បានសហការគ្នាសម្រួលឯកសារ និងផ្តល់ភាពស្របច្បាប់ដល់ពលករតាមរយៈ MoU បានចំនួនប្រមាណជា ៦៥ម៉ឺននាក់។
- បានប្តេជ្ញានឹងបញ្ចប់ការបញ្ជាក់អត្តសញ្ញាណដល់ពលករកម្ពុជាចំនួនប្រមាណ ១ម៉ឺននាក់ទៀត ឱ្យបានចប់មុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ នេះ។

២. ភាគីថៃបានឯកភាពអនុញ្ញាតឱ្យពលករកម្ពុជាដែលមិនទាន់មានឯកសារ ក្រោយពេលបញ្ចប់យុទ្ធនាការនេះ អាចត្រលប់ទៅប្រទេសកម្ពុជា ដើម្បីស្នើសុំធ្វើឯកសារស្របច្បាប់ ហើយវិលត្រលប់មកធ្វើការនៅប្រទេសថៃវិញជាពលករ MoU។

៣. ភាគីថៃនឹងសហការជាមួយភាគីកម្ពុជាដោយភាពទន់ភ្លន់ ក្នុងករណីរកឃើញថាមានបងប្អូនពលករកម្ពុជាដែលមិនទាន់មានឯកសារ ឬបាត់ឯកសារ ដោយសហការជូនដំណឹងមកស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ និងទីប្រឹក្សាទទួលបន្ទុកពលករ ដើម្បីរួមគ្នាដោះស្រាយនិងចេញលិខិតបើកផ្លូវដើម្បីពលករទាំងនោះបានវិលត្រលប់មកកម្ពុជាវិញ។

៤. ឯកភាពគ្នាបញ្ចប់យុទ្ធនាការជាស្ថាពរក្នុងការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៨ នេះតទៅ។ ជោគជ័យនៃយុទ្ធនាការនេះ គឺពិតជាបានផ្តល់ផលប្រយោជន៍ដ៏ធំធេងចំពោះប្រជាពលរដ្ឋនៃប្រទេសទាំងពីរ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជ្រាបជាព័ត៌មាន។

*ថ្ងៃចន្ទ ៦កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨*